# មន្ទីរកសិកម្មខេត្តកណ្ដាល

# ដំណាំម្រះ




អាស័យដ្ឋានទំនាក់ទំនង ផ្លូវលេខ ១០៣ (តាខ្មៅ)

ទំនាក់ទំនងទូរស័ព្ទ (០២៣ ៩៨៣ ៤៦១

(០១២ ៨២៤ ៤២៥



ឧបត្ថម្ភដោយ អង្គការវីវីអូប៊ី VVOB

ឆ្នាំ ២០១០


## ដំណាំម្រះ

### ១-ស្ថានភាពទូទៅ

ដំណាំប្រភេទនេះមានអត្ថប្រយោជន៏ច្រើន សំរាប់ការរស់នៅ។ គ្រប់ផ្នែកនៃប្រពន្ធ័សរីរាង្គត្រូវបានគេកែឆ្នៃ និងប្រើប្រាស់ជុំវិញជីវភាពប្រចាំថ្ងៃ ជាពិសេសដោយសារក្លិន រសជាតិ និងជីវជាតិ បានធ្វើឱ្យមានការនិយមចូលចិត្ត ដោយយកត្រួយ និងផ្លែមកប្រើប្រាស់ជាគ្រឿងផ្សំសំរាប់ម្ហូបអាហារ។

### ២-បច្ចេកទេសដាំដុះ

#### ១-ការជ្រើសរើស និង រៀបចំដី

ម្រះ គឺជាប្រភេទដំណាំដែលត្រូវការដីដែលមានជីជាតិ។ លក្ខខណ្ឌដីដែលអំណោយផលដល់ការដាំដុះម្រះ គឺដីជ្រាបទឹកស្រទាប់ដាំដុះជ្រៅ សំបូរទៅដោយសារធាតុចិញ្ចឹមជាពិសេស N, P, K, Ca និង Na។ ប្រភេទដីល្បាប់ល្បាយខ្សាច់ធ្វើឱ្យដំណាំម្រះលូតលាស់បានល្អ (ផះ=៦-៦.៨) ជាពិសេសដីតាមមាត់បឹង ស្ទឹង ទន្លេ ដែលសំបូរទៅដោយសារធាតុមមោកដែលបានមកពីសមាសធាតុស្ងួតនៃកាកសំណល់រុក្ខជាតិ។

**ការរៀបចំដីសំរាប់ដាំម្រះ** គេត្រូវភ្ជួរនៅពេលដីដែលស្រស់ទឹក ភ្ជួរឱ្យជ្រៅហាលដីឱ្យស្ងួត ហើយរាស់បំបែកដីឱ្យល្អិតប្រមូលស្មៅ និងកាកសំនល់ផ្សេងៗចេញ បន្ទាប់មកទៀតភ្ជួរប្រែដី និងរាស់ពង្រាបបំបែកដីឱ្យបានច្រើនសារ ហើយលើករងឱ្យខ្ពស់ដែលមានទទឹងរង ១១០-១២០សម (ដាំពីរជួរ)។ ក្រោយពីលើករងហើយ ត្រូវកាប់រណ្ដៅជំរៅ ៥-១០សម ជ្រុំដីឱ្យផុស នឹងរោយផេះបន្តិចៗនៅបាតរណ្ដៅ ដើម្បីការពារគ្រាប់ពីសត្វល្អិត ។

#### ២-ការជ្រើសរើសពូជ

ពូជជាកត្តាសំខាន់នៅក្នុងការដាំដុះ ពូជម្រះដែលគេនិយមដាំជាងគេគឺ ប្រភេទផ្លែធំវែង ក្រឡាឆ្នូតត្រង់ ផ្លែបៃតងខ្ចីរសជាតិមិនល្វីងគេហៅថា Bittergourd *Momordica charantica* ដែលគេនិយមដាំនៅប្រទេសចិនមុនគេ រហូតមកទល់បច្ចុប្បន្នពូជនេះត្រូវពេញនិយមទូទាំងទ្វីបអាស៊ី។

ដើម្បីឱ្យការដាំដុះទទួលបានផលល្អ គ្រាប់ពូជម្រះត្រូវរក្សាទុករយៈពេលពី ១-៤ខែ ប៉ុន្តែបើរក្សាទុកលើសពី ៨ខែឡើងទៅក្នុងលក្ខខណ្ឌធម្មតា នោះភាគរយដំណុះនឹងថយចុះច្រើន។ ដើម្បីដាំលើផ្ទៃដីមួយហិចតា គេត្រូវប្រើគ្រាប់ពូជទំងន់ ១.៥-១.៨ គីឡូក្រាម។

#### ៣-ការដាំដុះ

ម្រះជាប្រភេទដំណាំមួយដែលអាចដុះលូតលាស់បានពេញមួយឆ្នាំ ។ វិធីសាស្រ្តដាំដុះគេអាចធ្វើឡើងតាមពីររៀបគឺ ៖

ដាំដោយគ្រាប់ផ្ទាល់: មុនយកគ្រាប់ពូជទៅដាំដុះ គេត្រូវហាលថ្ងៃឱ្យក្ដៅរយៈពេល ១-២ម៉ោង មុននឹងយកទៅដាំ។ មុននិងដាំត្រូវជ្រោយដីក្នុងរណ្ដៅឱ្យផុស ហើយដាក់គ្រាប់ជំរៅ ១-២សម ចំនួន ២គ្រាប់/រណ្ដៅ រួចយកជីកំប៉ុស្ដមករោយពីលើឱ្យជិត រឺយកកំទេចចំបើងពុកៗមកគ្របពីលើរណ្ដៅបន្តិចៗ ហើយស្រោចទឹកឱ្យជោគពេលព្រឹក ល្ងាច ក្នុងរយៈពេល ៥-៧ថ្ងៃ ទើបវាដុះចេញពីដី។ ដើម្បីទទួលបានទិន្នផលល្អគេប្រើចន្លោះជួរ ៦០-៧០សម ចន្លោះគុម្ព ៣០-៤០សម។

**ការដាំដោយកូនបណ្តុះ** មុននឹងយកគ្រាប់ទៅបណ្តុះគេត្រូវយកគ្រាប់ពូជទៅហាលថ្ងៃឱ្យក្តៅរយៈពេល ១-២ម៉ោងមុននឹងយកទៅដាំដូចគ្នាទៅនិងការដាំដោយគ្រាប់ផ្ទាល់ដែរ។ ត្រូវយកគ្រាប់ទៅដាក់បណ្តុះក្នុងថ្នាល ឬកន្ទោងបណ្តុះ រហូតដល់គ្រាប់ដុះចេញស្លឹកដំបូង ២មូល។ ត្រូវគាស់កូនយកទៅដាំ (មុនគាស់ត្រូវស្រោចទឹកឱ្យជោគរយៈពេល ២០-៣០នាទី)។ គេដាំមួយគុម្ព មួយដើម ចន្លោះគុម្ព និងជួរដូចគ្នានិងការដាំដោយគ្រាប់ផ្ទាល់ដែរ។

**៤-តំរូវការទឹក នឹង ការស្រោចស្រព**

- ដំណាំម្រះចាប់ពីដាំរហូតដល់ដុះពន្លកវាត្រូវការសំណើមមធ្យម។ ចាប់ពីដុះចេញស្លឹកកំណើតរហូតដល់ម្រះចេញស្លឹកពិតចំនួន ៣-៤ វាត្រូវការសំណើមខ្លាំងជាងវគ្គដុះពន្លក ប៉ុន្តែក្រោយពីម្រះដុះចេញដៃសំរាប់តោងឡើងរហូតដល់ផ្លែវាត្រូវការសំណើមខ្លាំងជាងវគ្គនានារហូតដល់វគ្គប្រមូលផល។

- គេអាចស្រោចស្រពបានច្រើនវិធី ដូចជាតាមរយៈផ្សើម ឬតាមរយៈបញ្ចូលទឹកផ្ទាល់ដែលអាចធ្វើទៅបាន។ តាមការអះអាងរបស់លោក Siemonsma ឆ្នាំ ១៩៨២ ថានៅរដូវប្រាំងគេបញ្ចូលទឹកទៅតាមចន្លោះរងឱ្យជោគ ចាប់ពីវគ្គចេញផ្កា ក្នុងរយៈពេល ២-៣ថ្ងៃម្តងៗជាប្រចាំ ធ្វើឱ្យម្រះចេញផ្កាបានច្រើននិងផ្តល់ឱ្យទិន្នផលខ្ពស់។ ចំពោះការស្រោចដោយប៉ោតកំលាំងមនុស្ស ១ថ្ងៃ ២លើក ព្រឹក ល្ងាច តាមអត្រា ១០ម² ប្រើបរិមាណ ៥០-៦០លីត្រទឹក ក្នុងមួយថ្ងៃ។

**៥-ការជ្រុំជ្រោយដី និង កំចាត់ស្មៅ**

-ការជ្រុំជ្រោយដីមុនពេលដាំ មានអត្ថប្រយោជន៍យ៉ាងច្រើនដោយធ្វើឱ្យដីធូរ ធានាឱ្យមានការផ្លាស់ប្តូរបន្ទុកខ្យល់គ្រប់គ្រាន់ ធ្វើអោយជ្រាបទឹកបានល្អ រក្សាសំណើមបានយូរ បង្កឱ្យបាក់តេរីមានប្រយោជន៍នៅក្នុងដី បង្កើនសកម្មភាពបានកាន់តែខ្លាំង។

-ក្រោយពីជ្រុំជ្រោយដី និងដាំបានរយៈពេល ២០-៣០ថ្ងៃ ស្មៅបង្កើនសកម្មភាពដុះលូតលាស់ ដូច្នេះម្តងនេះគេត្រូវដកស្មៅចេញពីចំការដោយដៃ (គេមិនជ្រុំឬ ជ្រោយដីឡើយព្រោះវាបណ្តាលឱ្យដាច់រឹសរំខានដល់ការលូតលាស់របស់ដំណាំ)។

**៦-ការគ្របគល់ និង ដោតចំណារ**

-ការគ្របគល់មានអត្ថប្រយោជន៍យ៉ាងច្រើនដូចជា បន្ថយការដុះស្មៅ រក្សាសំណើមបានល្អ មិនធ្វើឱ្យដីហាប់ បន្ថយការហូរច្រោះ ឬហួតហែងនូវសារធាតុចិញ្ចឹម រក្សាកំដៅដីឱ្យនឹងល្អ កត្តាទាំងនេះចូលរួមអោយឫសលូតលាស់បានល្អសំរួលដល់ការស្រូបយកនូវសារធាតុចិញ្ចឹម។ វត្ថុធាតុផ្សេងៗដូចជា ស្មៅស្ងួត កំប្លោក ឬចំបើងស្រូវត្រូវបានគេយកមកគ្របអោយជិតពេញដីក្រោយពីជ្រុំជ្រោយដីរួច បន្ទាប់មកវែកចន្លោះទុកឱ្យទងម្រះលូតចេញមកលើគំរប។

- ម្រះជាប្រភេទដំណាំតោងឡើង គេអាចដោតចំណារ ឬផ្តល់សំណាញ់អោយវាតោងឡើង ជាពិសេសក្នុងវគ្គចេញដៃតោងដំបូង។

**៧-តំរូវការជីប្រើប្រាស់**

ដំណាំនេះត្រូវការសារធាតុសរីរាង្គជាច្រើន ជាពិសេសជីលាមកសត្វ និងជីកំប៉ុស្តិ៍។ គេត្រូវដាក់សារធាតុសរីរាង្គ ចំនួន ១០-១៥តោន/ហិចតា ដោយរាស់លប់ទៅក្នុងដី។

**៨-ផ្លែ និង ការការពារ**

ក្រោយពីបន្តពូជ ផ្ការបស់វាស្រពោនហើយជ្រុះ ពេលនោះវាឱ្យកំណើតទៅជាផ្លែ។ គេអាចជ្រើសរើសផ្លែ (ក្តិប) សំរាប់រក្សាទុកឱ្យផ្លែធំបាន ដោយពិនិត្យមើលទងធំវែង ផ្លែមានក្រឡាត្រង់ ក្តិតត្រង់ ថ្លោសទ្រវែងមានពណិបៃតងរលោង ក្តិបនោះអាចបង្កើតទៅជាផ្លែធំបាន។ ក្រោយពីជ្រើសរើសគេត្រូវយកក្រដាស់មករុំក្តោបក្តិបដើម្បីកុំឱ្យរុយទិចផ្លែ។

**៣-ការប្រមូលផល**

គេអាចដឹងនូវរយៈពេលប្រមូលផលបានចាប់ពីផ្ការីកហើយស្រពោនរយៈពេល ១៥-២០ថ្ងៃ ឬ ក្រោយពីដាំបានរយៈពេល ៤៥-៥០ថ្ងៃ។ ម្រះប្រមូលផលច្រើនដង គេអាចប្រមូលផល ២-៣ថ្ងៃម្តង ហើយការប្រមូលផលធ្វើឡើង ចំនួនពី ៨-១០លើក អាស្រ័យទៅលើការដាំដុះ និងថែទាំ។ នៅតំបន់អាស៊ីទិន្នផលមធ្យមពី ៨-១២តោន/ហ.ត ។